**សំណួរ**

**តើអាជ្ញាធរអាចកម្រិតសិទ្ធិមនុស្សបានឬទេ (restriction of rights)?**

**ចម្លើយ**

តាមទ្រឹស្តី កិច្ចសន្យាសង្គម (social contract) សិទ្ធិសេរីភាព ទាមទារឲ្យមានការកម្រិត ដើម្បីអាចអនុវត្តបាន បង្ការមិនឲ្យមានការបំពានហួសដែនប្រាស្រ័យសិទ្ធិ ដែលអាចនាំឲ្យមានចលាចលក្នុងសង្គម។ តើអាជ្ញាធរអាចកម្រិតសិទ្ធិបានដែរឬទេ និងក្នុងករណីណាខ្លះ?

កតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ ឆ្នាំ ១៩៦៧ មាត្រា ១៩ បានចែងថា៖ *សេរីភាពសំដែងមតិ....ស្ថិតក្រោមការកម្រិតជាក់លាក់ ដែលត្រូវបានចែងក្នុងច្បាប់ និងចាំបាច់៖ ក. ដើម្បីការពារសិទ្ធិ ឬកិត្តិយសបុគ្គលដទៃ។ ខ. ដើម្បីការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ ឬសុខមាលភាពសាធារណៈ*។ នេះជាឧទាហរណ៍ នៃការកម្រិតសិទ្ធិ ដែលអនុញ្ញាតដោយសន្ធិសញ្ញាសិទ្ធិមនុស្ស។ វាជាការកម្រិតសិទ្ធិ មានស្រាប់ភ្ជាប់ជាមួយនឹងប្រភេទសិទ្ធិ ជាក់លាក់មួយចំនួន (inherent limitation of rights)។ វាតម្រូវឲ្យមានការកម្រិតសិទ្ធិ ដើម្បីកុំឲ្យមានការប៉ះពាល់ដល់សង្គម។ ឧទាហរណ៍ បុគ្គលមានសិទ្ធិបញ្ចេញមតិ ក៏ប៉ុន្តែប្រសិនការបញ្ចេញមតិ បង្កប់នូវការញុះញង់នាំឲ្យរើសអើង ឬហិង្សា នោះវានឹងមិនត្រឹមត្រូវទេ។ កថាខ័ណ្ឌទី ២ នៃមាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ ដោយប្រយោល បានចែងអំពីការកម្រិតសិទ្ធិ។

ក្រៅពីប្រភេទនៃការកម្រិតសិទ្ធិខាងលើនេះ កតិកាសញ្ញាដដែលមាត្រា ៤ បានចែងអនុញ្ញាតឲ្យមានការកម្រិត ឬ ផ្អាកអនុវត្តសិទ្ធិមួយចំនួន ក្នុងពេលមានគ្រោះអាសន្នសាធារណៈ រឹកររដល់ប្រទេសជាតិ។ នេះទុកច្រក ដើម្បីឲ្យរដ្ឋអាចចាត់វិធានការទប់ស្កាត់នូវស្ថានការណ៍កាន់តែអាក្រក់។ ជាក់ស្តែង ឧទាហរណ៍ ក្នុងពេលមានគ្រោះអាសន្ន ដូចជាសង្គ្រាម រដ្ឋអាចចេញច្បាប់បម្រាមគោចរ ដោយកម្រិត ឬហាមឃាត់ការធ្វើដំណើរ ដែលនេះ ជាការកម្រិតសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ (right to freedom of movement)។ ទោះបីជាយ៉ាងនេះក្តី សិទ្ធិខ្លះនឹងមិនត្រូវបានអនុញ្ញាតឲ្យមានការកម្រិត ឬផ្អាកការអនុវត្តទេ។ សូមមើលអត្ថបទ សំណួរចម្លើយ ស្តីពី សិទ្ធិដាច់ខាត (absolute rights) ជាបន្ថែមទៀត។

Further readings: Homa Mahdavi Pour, *Limitation of Individuals' Rights and Freedoms and Its Principles in the Constitution of the Islamic Republic of Iran*, 9(2) Journal of Politics and Law, 2016; Kathleen Ann Ruane, Freedom of Speech and Press: Exceptions to the First Amendment, 2014; European Court of Human Rights, Guide on Article 18 of the European Convention on Human Rights, Limitation on use of restriction on rights, 2018.